សមាគមរដ្ឋម៉ាសាជូសេត (The Commonwealth of Massachusetts)
ក្រសួងអប់រំ និងថែទាំសុខភាពកុមារ (Department of Early Education and Care)

គោលការណ៍	
ដំណើរការត្រួតពិនិត្យកំណត់ហេតុប្រវត្តិក្រសួង EEC តាមប្រភេទកម្មវិធីសម្រាប់ប្រភេទកម្មវិធីទាំងអស់	**ប្រតិបត្តិការទីវាល - កម្មវិធីដែលចេញអាជ្ញាប័ណ្ណ និងផ្តល់មូលនិធិទាំងអស់។**
កាលបរិច្ឆេទចាប់ផ្តើមមានប្រសិទ្ធភាព៖ 22 សីហា 2023	

ក្រសួងអប់រំ និងថែទាំសុខភាពកុមារ (Department of Early Education and Care, EEC) ចេញអាជ្ញាប័ណ្ណ និងការយល់ព្រមដល់អ្នកដាក់ពាក្យសុំក្នុងប្រភេទកម្មវិធីផ្សេងៗ។ ប្រភេទកម្មវិធីនីមួយៗមានច្បាប់ផ្សេងៗគ្នា ទាក់ទងនឹងការត្រួតពិនិត្យកំណត់ហេតុប្រវត្តិ (BRCs)។ សេចក្តីសង្ខេបនៃតម្រូវការទាមទារ EEC BRC មានដូចខាងក្រោម៖

<u>ការថែទាំកុមារគ្រួសារ</u>
នេះរួមបញ្ចូលទាំងអ្នកអប់រំផ្តែកថែទាំកុមារជាគ្រួសារ (FCC)
ក៏ដូចជាសមាជិកគ្រួសាររបស់ពួកគេដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ៖
បុគ្គលជាទៀងទាត់នៅក្នុងបរិវេណដែលមានអាយុ 15 ឆ្នាំឬលើសពីនេះ; ជំនួយការ FCC ទាំងអស់;
និងនរណាម្នាក់ដែលផ្តល់សេវាកម្មក្នុងនាម ឬអ្នកដែលពាក់ព័ន្ធ ឬមានវត្តមាននៅក្នុងកម្មវិធីបែបនេះ។
ឧទាហរណ៍បុគ្គល ដែលពាក់ព័ន្ធរួមមានបុគ្គលិកប្រព័ន្ធ FCC និងបុគ្គលិកដឹកជញ្ជូន។ *<u>សូមមើល</u>*
តារាងសម្ព័ន្ធភាគីទីបី (ខាងក្រោម)។ អ្នកស្ម័គ្រចិត្តនៅក្នុងផ្ទះ FCC
ត្រូវតែដំណើរការក្រោមតួនាទីរបស់បុគ្គលជាទៀងទាត់នៅក្នុងបរិវេណ មានន័យថាបុគ្គល បែបនេះត្រូវតែមាន EEC BRC ជានិច្ច។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះអ្នកដាក់ពាក្យសុំ FCC រួមមាន៖

- តម្រូវការទាមទារ EEC BRC គឺសម្រាប់ការត្រួតពិនិត្យដោយផ្អែកលើស្នាមម្រាមដៃ ព័ត៌មានស្តីពីកំណត់ហេតុ ឧក្រិដ្ឋកម្ម (CORI), ក្រសួងកុមារ និងគ្រួសារ (DCF), ព័ត៌មានចុះបញ្ជីជនល្មើសផ្លូវភេទ (SORI), បញ្ជីឈ្មោះ ជនល្មើសផ្លូវភេទជាតិ (NSOR) ហើយករណីដែលអាចអនុវត្តបាន ទាំងអស់ចេញ- ការត្រួតពិនិត្យរបស់រដ្ឋដែល កំណត់ដោយកម្មវិធីជំនួយផ្តែកថែទាំ និងអភិវឌ្ឍន៍កុមារ (CCDBG)។
- អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណ FCC និងជំនួយការត្រូវទទួលរងការដកសិទ្ធិជាក់លាក់ដែលកំណត់ដោយច្បាប់សហព័ន្ធ។
- អ្នកដាក់ពាក្យសុំ FCC មិនអាចធ្វើការក្នុងស្ថានភាពបណ្តោះអាសន្នបានទេ; ផ្តួយទៅវិញពួកគេត្រូវតែបំពេញ ដំណើរការ BRC ទាំងស្រុង និងទទួលបានការរកឃើញសមស្រប មុនពេលពួកគេអាចទទួលបានអាជ្ញាប័ណ្ណ ឬការយល់ព្រម។
- សមាជិកគ្រួសារទាំងអស់ និងបុគ្គលជាទៀងទាត់នៅក្នុងបរិវេណត្រូវតែចាត់ទុកថាសមរម្យ មុនពេលអ្នកអប់រំ FCC អាចចេញអាជ្ញាប័ណ្ណ។
- ភាគីទីបីទាំងអស់ដែលមានទំនាក់ទំនងជាមួយកម្មវិធី FCC ដែលអាចមានសិទ្ធិចូលប្រើដោយគ្មានការត្រួតពិនិត្យ ចំពោះកុមារ ត្រូវតែបំពេញ BRC ទោះបីជាពួកគេមានវត្តមាននៅលើមូលដ្ឋានបណ្តោះអាសន្នក៏ដោយ។

<u>ការថែទាំកុមារជាក្រុម និងតាមអាយុសិក្សា</u>
កម្មវិធីថែទាំកុមារក្នុងក្រុម និងតាមអាយុសិក្សា (GSA) ផ្តល់ជូនការអប់រំ
និងការថែទាំកុមារតូចៗនៅក្នុងការកំណត់ ផ្តែកលើសហគមន៍នៅខាងក្រៅផ្ទះកុមារ ឬអ្នកអប់រំ។
អ្នកទទួលអាជ្ញាប័ណ្ណក្នុងក្រុម និងកម្មវិធីថែទាំកុមារតាមអាយុសិក្សា រួមមានបុគ្គលណាម្នាក់ដែលចង់ទទួលបាន បន្តថ្មី ឬរក្សាអាជ្ញាប័ណ្ណក្រសួង EEC ឬការអនុម័ត។ និយោជិត និងអ្នកហាត់ការ ទាំងអស់ដែលមានការងារ ឬស្ម័គ្រចិត្តក្នុងសមត្ថភាពអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ននៅក្នុងកម្មវិធីថែទាំកុមារជាក្រុម និងតាម អាយុសិក្សា ត្រូវតែបំពេញ EEC BRC ដោយមិនគិតពីថាតើបុគ្គលទាំងនោះមានសិទ្ធិចូលប្រើប្រាស់ដោយគ្មានការត្រួតពិនិត្យ ចំពោះកុមារ។ លើសពីនេះទៀតក្រសួង EEC ទាមទារ BRC

សម្រាប់អ្នកស្ម័គ្រចិត្តដែលមានសមត្ថភាពគ្មានការត្រួតពិនិត្យ នៅក្នុងកម្មវិធីក្រសួង EEC ដែលមានអាជ្ញាប័ណ្ណ អនុម័ត ឬផ្តល់មូលនិធិ។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះកម្មវិធី និងអ្នកដាក់ពាក្យសុំ GSA រួមមាន៖

- តម្រូវការទាមទាររបស់ EEC BRC គឺសម្រាប់ការត្រួតពិនិត្យផ្អែកលើស្មាមម្រាមដៃ CORI, DCF, SORI និង NSOR ហើយករណីដែលអាចអនុវត្តបាន ការត្រួតពិនិត្យក្រៅរដ្ឋទាំងអស់ ដែលកំណត់ដោយ CCDBG។
- អ្នកដាក់ពាក្យសុំ GSA ត្រូវទទួលរងការដកសិទ្ធិដាក់លាក់ដែលកំណត់ដោយច្បាប់សហព័ន្ធ។
- ក្រសួង EEC ត្រូវតែពិនិត្យមើលព័ត៌មាន BRC ទាំងអស់ ដើម្បីកំណត់ថាតើប្រវត្តិរបស់អ្នកដាក់ពាក្យសុំគឺសមរម្យនៅក្រោមច្បាប់រដ្ឋ និងសហព័ន្ធ ហើយមិនអាចផ្ទេរការពិនិត្យឡើងវិញចំពោះកម្មវិធីបានទេ។
- អ្នកទទួលអាជ្ញាប័ណ្ណត្រូវតែមានការសម្រេចចិត្តជារួម "សមរម្យ" មុនពេលអាជ្ញាប័ណ្ណមួយអាចត្រូវចេញ ឬបន្តថ្មី។
- អ្នកគ្រប់គ្រងកម្មវិធី BRC និយោជិត អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត (ករណីដែលអាចអនុវត្តបាន) អាចធ្វើការ
  ឬមានវត្តមាននៅក្នុងស្ថានភាពបណ្តោះអាសន្នដែលមានការត្រួតពិនិត្យតាមការយល់ព្រមពីក្រសួង EEC។ ការត្រួតពិនិត្យត្រូវតែដោយផ្ទាល់ និងថេរ
  ហើយអាចអនុវត្តដោយបុគ្គលិកណាមួយនៃកម្មវិធីដែលមានការកំណត់ ភាពសមស្របនៃក្រសួង EEC បច្ចុប្បន្ន។
- ការងារតាមលក្ខខណ្ឌមិនអាចអនុវត្តបានចំពោះអ្នកដាក់ពាក្យសុំ GSA ទេ។
- ភាគីទីបីទាំងអស់ (មិនមែនបុគ្គលិក) ក្នុងកម្មវិធីថែទាំកុមារ GSA
  ដែលអាចមានសិទ្ធិចូលប្រើប្រាស់កុមារដោយ គ្មានការត្រួតពិនិត្យ ត្រូវតែបំពេញ BRC
  ទោះបីជាពួកគេមានវត្តមាននៅលើមូលដ្ឋានបណ្តោះអាសន្នក៏ដោយ។

<u>កម្មវិធីដែលផ្តល់មូលនិធិ</u>
កម្មវិធីដែលទទួលបានមូលនិធិតាមរយៈប័ណ្ណទូទាត់ប្រាក់ ឬកិច្ចសន្យាជំនួយហិរញ្ញវត្ថុការថែទាំកុមារ
ដែលត្រូវបានផ្តល់ មូលនិធិដោយក្រសួង EEC ប៉ុន្តែមិនតម្រូវឱ្យទទួលបានអាជ្ញាប័ណ្ណពីក្រសួង EEC នោះ
ត្រូវតែបំពេញ EEC BRC។ និយោជិតទាំងអស់ត្រូវស្ថិតនៅក្រោម EEC BRC
ដោយមិនគិតពីថាតើពួកគេអាចមានសិទ្ធិចូលប្រើប្រាស់ដោយ គ្មានការត្រួតពិនិត្យចំពោះកុមារនោះទេ។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះកម្មវិធីដែលផ្តល់មូលនិធិរួមមាន៖

- តម្រូវការទាមទាររបស់ EEC BRC គឺសម្រាប់ការត្រួតពិនិត្យផ្អែកលើស្មាមម្រាមដៃ CORI, DCF, SORI និង NSOR ហើយករណីដែលអាចអនុវត្តបាន ការត្រួតពិនិត្យក្រៅរដ្ឋទាំងអស់ ដែលកំណត់ដោយ CCDBG។
- អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវទទួលរងការដកសិទ្ធិដាក់លាក់ដែលកំណត់ដោយច្បាប់សហព័ន្ធ។
- ក្រសួង EEC ត្រូវតែពិនិត្យមើលព័ត៌មាន BRC ទាំងអស់ ដើម្បីកំណត់ថាតើប្រវត្តិរបស់អ្នកដាក់ពាក្យសុំគឺសមរម្យនៅក្រោមច្បាប់រដ្ឋ និងសហព័ន្ធ ហើយមិនអាចផ្ទេរការពិនិត្យឡើងវិញចំពោះកម្មវិធីបានទេ។
- អ្នកគ្រប់គ្រងកម្មវិធីដែលបានកំណត់នៅក្នុងកម្មវិធីដែលផ្តល់មូលនិធិ
  ត្រូវតែមានការសម្រេចចិត្តជារួម "សមរម្យ" មុនពេលការផ្តល់មូលនិធិនឹងត្រូវចេញ ឬបន្តថ្មី។
- និយោជិត អ្នកហាត់ការ និងអ្នកស្ម័គ្រចិត្ត (ករណីដែលអាចអនុវត្តបាន) អាចធ្វើការ
  ឬមានវត្តមាននៅក្នុង ស្ថានភាពបណ្តោះអាសន្នដែលមានការត្រួតពិនិត្យតាមការយល់ព្រមពីក្រសួង EEC។ ការត្រួតពិនិត្យត្រូវតែដោយផ្ទាល់ និងថេរ
  ហើយអាចអនុវត្តដោយបុគ្គលិកណាមួយនៃកម្មវិធីដែលមានការកំណត់ ភាពសមស្របនៃក្រសួង EEC បច្ចុប្បន្ន។
- ការងារតាមលក្ខខណ្ឌមិនអាចអនុវត្តបានចំពោះកម្មវិធីដែលផ្តល់មូលនិធិទេ។
- ភាគីទីបីទាំងអស់ (មិនមែនបុគ្គលិក)
  នៅក្នុងកម្មវិធីដែលផ្តល់មូលនិធិដែលអាចមានសិទ្ធិចូលប្រើដោយគ្មាន ការត្រួតពិនិត្យចំពោះកុមារនោះ ត្រូវតែបំពេញ BRC ទោះបីជាពួកគេមានវត្តមាននៅលើមូលដ្ឋានបណ្តោះអាសន្នក៏ដោយ។

<u>អ្នកមើលថែទាំដែលមិនមែនជាសាច់ញាតិនៅផ្ទះ</u>
បុគ្គលដែលទទួលបានមូលនិធិពីមូលនិធិអភិវឌ្ឍន៍ការថែទាំកុមារ (CCDF) តាមរយៈក្រសួង EEC
ដើម្បីផ្តល់ការថែទាំកុមារ
ដែលគាំទ្រដោយជំនួយហិរញ្ញវត្ថុដល់កុមារដែលមិនពាក់ព័ន្ធនៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់កុមារនោះ ត្រូវតែបំពេញ EEC BRC។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះកម្មវិធីអ្នកមើលថែទាំដែលមិនមែនជាសាច់ញាតិនៅផ្ទះ រួមមាន៖

- តម្រូវការទាមទាររបស់ EEC BRC គឺសម្រាប់ការត្រួតពិនិត្យផ្អែកលើស្នាមម្រាមដៃ CORI, DCF, SORI និង NSOR ហើយករណីដែលអាចអនុវត្តបាន ការត្រួតពិនិត្យក្រៅរដ្ឋទាំងអស់ ដែលកំណត់ដោយ CCDBG។
- អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវទទួលរងការដកសិទ្ធិជាក់លាក់ដែលកំណត់ដោយច្បាប់សហព័ន្ធ។
- អ្នកដាក់ពាក្យសុំដែលមិនមែនជាសាច់ញាតិនៅក្នុងផ្ទះ មិនអាចធ្វើការក្នុងស្ថានភាពបណ្តោះអាសន្ន ឬតាមលក្ខខណ្ឌបានទេ ហើយត្រូវតែមានការសម្រេចចិត្តជារួម "សមរម្យ" មុនពេលទទួលបានមូលនិធិក្រសួង EEC ឬមុនពេលក្រសួង EEC នឹងចេញកិច្ចព្រមព្រៀងប័ណ្ណធានា។

<u>អ្នកមើលថែទាំសាច់ញាតិ</u>
បុគ្គលដែលជាជីតា មីង ពូ ឬបងប្អូនបង្កើតដោយឈាម អាពាហ៍ពិពាហ៍ ឬការយកកូនចិញ្ចឹម ដែលទទួលបានមូលនិធិ តាមរយៈក្រសួង EEC ដើម្បីផ្តល់ជូនការថែទាំដល់កុមារនៅក្នុងផ្ទះ ឬផ្ទះកុមារ។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអាចអនុវត្តបានចំពោះអ្នកមើលថែទាំសាច់ញាតិ រួមមាន៖
- តម្រូវការទាមទារ EEC BRC គឺសម្រាប់ការបញ្ចប់ការត្រួតពិនិត្យ SORI និងការត្រួតពិនិត្យ NSOR ក្នុងករណីត្រូវអនុវត្ត។
- ការរកឃើញពីការត្រួតពិនិត្យ SORI ឬ NSOR នឹងបង្កើតការដកសិទ្ធិជាកាតព្វកិច្ច។
- អ្នកដាក់ពាក្យសុំដែលទាក់ទងគ្នាមិនអាចធ្វើការក្នុងស្ថានភាពបណ្តោះអាសន្ន ឬតាមលក្ខខណ្ឌបានទេ ហើយត្រូវតែមានការសម្រេចចិត្តជារួម "សមរម្យ" ដោយសារមុនពេលទទួលបានមូលនិធិក្រសួង EEC។

<u>កម្មវិធីលំនៅដ្ឋាន និងទីភ្នាក់ងាររកទីកន្លែង</u>
កម្មវិធីលំនៅដ្ឋាន និងរកទីកន្លែង (R&P) ផ្តល់ជូនការថែទាំ និងសេវាកម្មដល់កុមារ ទាំងដោយការព្រមព្រៀងជាមួយ ឪពុកម្តាយ ឬអាណាព្យាបាល ដោយមានកិច្ចសន្យាជាមួយទីភ្នាក់ងាររដ្ឋ ឬជាលទ្ធផលនៃអ្នកជំនាញណែនាំបន្ត ដោយតុលាការនៃយុត្តាធិការមានសមត្ថកិច្ច។
អ្នកទទួលអាជ្ញាប័ណ្ណនៅក្នុងកម្មវិធីលំនៅដ្ឋាន ឬរកទីកន្លែងស្នាក់នៅ រួមមានអ្នកដែលស្វែងរក ដើម្បីទទួលបាន បន្តថ្មី ឬរក្សាអាជ្ញាប័ណ្ណក្រសួង EEC ឬការយល់ព្រមសម្រាប់កម្មវិធីលំនៅដ្ឋាន ឬទីភ្នាក់ងាររកទីកន្លែង។ និយោជិត និងអ្នកហាត់ការទាំងអស់ដែលធ្វើការ ឬសហការក្នុងសមត្ថភាពអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នក្នុងកម្មវិធីលំនៅដ្ឋាន និងរកទីកន្លែង ត្រូវតែបំពេញ EEC BRC ដោយមិនគិតពីថាតើបុគ្គលទាំងនោះ មានសិទ្ធិចូលប្រើប្រាស់ដោយគ្មានការត្រួតពិនិត្យចំពោះកុមារ។
អ្នកដែលស្ម័គ្រចិត្តក្នុងសមត្ថភាពដែលគ្មានការត្រួតពិនិត្យ នៅក្នុងកម្មវិធី R&P ក៏ជាកម្មវត្ថុ EEC BRC ផងដែរ។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះកម្មវិធី R&P រួមមាន៖
- តម្រូវការទាមទារ EEC BRC រួមមានការត្រួតពិនិត្យផ្អែកលើស្នាមម្រាមដៃ, CORI, DCF និង SORI។ លើសពីនេះទៀតក្នុងករណីដែលអាចអនុវត្តបាន អ្នកដាក់ពាក្យសុំកម្មវិធីលំនៅដ្ឋាននឹងត្រូវទទួលការត្រួតពិនិត្យ សុខុមាលភាពកុមារនៅក្រៅរដ្ឋ។
- ច្បាប់សហព័ន្ធមិនកំណត់អ្នកដាក់ពាក្យសុំទាំងនេះឱ្យមានការដកសិទ្ធិជាកាតព្វកិច្ចទេ; ទោះយ៉ាងណាក៏ដោយ ក៏ការចោទប្រកាន់ដែលរកឃើញនៅលើរបាយ Table of Disqualifications Offenses – Mandatory Disqualifications នឹងត្រូវបានចាត់ទុកថាជាការដកសិទ្ធិសន្ធត និងតម្រូវឱ្យមានការត្រួតពិនិត្យឡើងវិញ BRC។
- អ្នកទទួលអាជ្ញាប័ណ្ណត្រូវតែមានការសម្រេចចិត្តជារួម "សមរម្យ" មុនពេលអាជ្ញាប័ណ្ណមួយអាចត្រូវចេញ។
- ឬបន្តថ្មី។
- ការងារតាមលក្ខខណ្ឌមិនអាចអនុវត្តបានចំពោះអ្នកដាក់ពាក្យសុំទេ។
- ការងារតាមលក្ខខណ្ឌមិនអាចអនុវត្តបានចំពោះអ្នកដាក់ពាក្យសុំទាំងនេះ។
- អ្នកដាក់ពាក្យសុំលំនៅដ្ឋាន និងរកទីកន្លែងត្រូវតែបំពេញដំណើរការ BRC ទាំងស្រុង និងទទួលបានការស្វែងរក សមស្រប មុនពេលពួកគេអាចចាប់ផ្តើមការងារនៅក្នុងកម្មវិធីមួយ។

<u>ឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម</u>
កម្មវិធីទាក់ទងនឹងការយកកូនចិញ្ចឹម និងការថែទាំកូនចិញ្ចឹម ត្រូវតែបំពេញ EEC BRC។
លក្ខខណ្ឌទាមទារពាក់ព័ន្ធនឹង អ្នកដាក់ពាក្យសុំបច្ចុប្បន្ន និងអនាគតសម្រាប់ឪពុកម្តាយចិញ្ចឹម ឬកូនចិញ្ចឹម និងសមាជិកគ្រួសារឪពុកម្តាយចិញ្ចឹម ដែលមានអាយុចាប់ពី 15 ឆ្នាំឡើងទៅ ដែលមិនមែនជាកម្មវត្ថុយុត្តាធិការរបស់ DCF។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអនុវត្តចំពោះឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹម រួមមាន៖
- តម្រូវការទាមទារ EEC BRC សម្រាប់ការត្រួតពិនិត្យផ្អែកលើស្នាមម្រាមដៃ, CORI និង SORI។

- ការត្រួតពិនិត្យ DCF ត្រូវបំពេញដោយផ្ទាល់តាមរយៈ DCF។
- អ្នកដាក់ពាក្យសុំទាំងនេះ មិនត្រូវបានដកសិទ្ធិជាកាតព្វកិច្ចទេ។
- នៅខណៈពេលក្រសួង EEC បំពេញការត្រួតពិនិត្យទាំងនេះ ក្រសួង EEC មិនចេញការរកឃើញណាមួយទាក់ទងនឹងភាពសមស្របនោះទេ។

<u>សាខាភាគីទីបី</u>
ក្រសួង EEC មិនចេញអាជ្ញាប័ណ្ណ ឬការផ្តល់មូលនិធិដល់សាខាភាគីទីបី
ដែលអាចភ្ជាប់ជាមួយប្រភេទកម្មវិធីនៃក្រសួង EEC ដែលចេញអាជ្ញាប័ណ្ណ អនុម័ត
ឬផ្តល់មូលនិធិណាមួយឡើយ។ ក្រុមហ៊ុន ឬបុគ្គលដែលជាសាខាមានទំនាក់ទំនង
ជាទៀងទាត់ជាមួយកម្មវិធីដែលមានអាជ្ញាប័ណ្ណ អនុម័ត ឬផ្តល់មូលនិធិពី ក្រសួង EEC តាមរយៈការងារ
កិច្ចសន្យា ឬកិច្ចព្រមព្រៀងក្រៅផ្លូវការជាមួយកម្មវិធី
ឬឪពុកម្តាយក្នុងគោលបំណងផ្តល់សេវាកម្មជំនួសឱ្យកម្មវិធីដល់កុមារ ដែលចូលរួម។

ឧទាហរណ៍សាខាភាគីទីបីរួមមានៈ បុគ្គលិកដឹកជញ្ជូន អ្នកម៉ៅការ អ្នកម៉ៅការបន្ត អ្នកលក់
អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ បុគ្គលិកប្រព័ន្ធ FCC គ្រូបង្វឹក និងអ្នកព្យាបាលរោគ
ដែលជួយតាមលក្ខណៈដែលនាំឱ្យពួកគេមានសិទ្ធិចូលប្រើដោយ គ្មានការត្រួតពិនិត្យចំពោះកុមារ។

សមាសធាតុសំខាន់ៗមួយចំនួននៃបទប្បញ្ញត្តិ EEC BRC ដែលអាចអនុវត្តបានចំពោះសាខាភាគីទីបី រួមមានៈ
- តម្រូវការទាមទារ EEC BRC សម្រាប់ការត្រួតពិនិត្យផ្អែកលើស្នាមម្រាមដៃ, CORI, DCF និង SORI។
- NSOR និងការត្រួតពិនិត្យក្រៅរដ្ឋទាំងអស់ ដែលកំណត់ដោយ CCDBG ត្រូវបានទាមទារចំពោះសាខាភាគីទីបីរបស់ GSA និង FCC។
- ការត្រួតពិនិត្យសុខុមាលភាពកុមារនៅក្រៅរដ្ឋ ត្រូវបានទាមទារអ្នកដាក់ពាក្យសុំស្នាក់នៅដែលអាចអនុវត្តបានណាមួយ។
- អ្នកដាក់ពាក្យសុំដែលជាសាខាត្រូវទទួលរងការដកសិទ្ធិជាកាតព្វកិច្ច
  លុះត្រាតែអ្នកដាក់ពាក្យសុំជាប់ពាក់ព័ន្ធ ជាមួយកម្មវិធីលំនៅដ្ឋាន និងរកទីកន្លែង
  ដែលការចោទប្រកាន់របស់ពួកគេនឹងត្រូវបានចាត់ទុកថាជា
  ការដកសិទ្ធិដែលទាមទារឱ្យមានការត្រួតពិនិត្យឡើងវិញ BRC។
- សាខាភាគីទីបីមិនមានកម្មវត្ថុការជួលបណ្តោះអាសន្នទេ។

តើនៅពេលណាដែលភាគីទីបីជាកម្មវត្ថុ EEC BRC?

តួនាទី	**ការចូលប្រើដែលមានការត្រួតពិនិត្យ?**	**BRC**
គ្រូបង្ហាត់	បានត្រួតពិនិត្យ	ទេ
គ្រូបង្ហាត់	មិនបានត្រួតពិនិត្យ	បាទ/ចាស៎
បុគ្គលិកប្រព័ន្ធ FCC	តែងតែបានសន្មតថាជាទៀងទាត់នៅក្នុងបរិវេណ និងមិនបានត្រួតពិនិត្យ	បាទ/ចាស៎
បុគ្គលិកដឹកជញ្ជូន	តែងតែបានសន្មតថាមិនបានត្រួតពិនិត្យ	បាទ/ចាស៎
គ្រូបន្ថែមកម្មវិធីសិក្សា	បានត្រួតពិនិត្យ	ទេ
គ្រូបន្ថែមកម្មវិធីសិក្សា	មិនបានត្រួតពិនិត្យ	បាទ/ចាស៎
អ្នកព្យាបាលរោគ	បានត្រួតពិនិត្យ	ទេ
អ្នកព្យាបាលរោគ	មិនបានត្រួតពិនិត្យ	បាទ/ចាស៎
បុគ្គលិកអន្តរាគមន៍បឋម	បានត្រួតពិនិត្យ (ត្រូវតែស្ថិតក្នុងស្ថានភាពនេះជានិច្ច)	ទេ
អ្នកលក់	បានត្រួតពិនិត្យ	ទេ
អ្នកលក់	មិនបានត្រួតពិនិត្យ	បាទ/ចាស៎
អ្នកម៉ៅការ / អ្នកម៉ៅការបន្ត	បានត្រួតពិនិត្យ	ទេ
អ្នកម៉ៅការ / អ្នកម៉ៅការបន្ត	មិនបានត្រួតពិនិត្យ	បាទ/ចាស៎
អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ	បានត្រួតពិនិត្យ	ទេ
អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ	មិនបានត្រួតពិនិត្យ	បាទ/ចាស៎